USAID
FROM THE AMERICAN PEOPLE

SHARE
Supporting Holistic & Actionable
Research in Education

# សេចក្ដីសង្ខេបការសិក្សា

## ការសិក្សាដើម្បីកែលម្អប្រព័ន្ធប្រតិបត្តិការធនធានសៀវភៅនៅកម្ពុជា

មិថុនា ២០២៤
ទាញយកអត្ថបទស្រាវជ្រាវពេញ
doi:10.7274/vh53ws8909

### អំពីគម្រោង

ឧបត្ថម្ភគាំទ្រដោយ ៖ USAID

រយៈពេល ៖ ២០២២ - ២០២៣

អនុវត្តន៍គម្រោងដោយ ៖ CDRI

(វិទ្យាស្ថានបណ្ដុះបណ្ដាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា)

### វិធីសាស្ត្រស្រាវជ្រាវ

**៨០៧**
ការស្រង់មតិអនឡាញ
នាយកសាលាបឋមសិក្សា
២៥ ខេត្ត-ក្រុង

**៣១**
កិច្ចសម្ភាសន៍
អ្នកពាក់ពន្ធ័៥២រូប
ប្រុស៖ ៤៥ | ស្រី៖ ៧
៥ ខេត្ត-ក្រុង

**កម្រិតយុទ្ធសាស្ត្រ**
រាជរដ្ឋាភិបាល
ដៃគូអភិវឌ្ឍន៍
ក្រុមហ៊ុនឯកជន

**កម្រិតប្រតិបត្តិការ**
ការិយាល័យអប់រំខេត្ត និងស្រុក
នាយកសាលាបឋមសិក្សា
គណៈកម្មាធិការគាំទ្រសាលា

## ទិដ្ឋភាពទូទៅនៃការសិក្សា

គម្រោងសិក្សានេះមានបំណងស្វែងយល់ពីរបៀបកែលម្អប្រព័ន្ធផ្គត់ផ្គង់សៀវភៅកម្រិតបឋមសិក្សានៅក្នុងប្រទេសដែលមានចំណូលមធ្យមកម្រិតទាប(LMIC)ដោយពិនិត្យមើលករណីចំនួនបីនៅក្នុងប្រទេសកម្ពុជា ហុងឌូរ៉ាស និងរ៉ាន់ដា។ នៅកម្ពុជា យើងសិក្សាលើប្រព័ន្ធ Track and Trace (TnT-ធីអេនធី)។

## លទ្ធផលស្រាវជ្រាវ

**សំណួរស្រាវជ្រាវទី ១៖**
***តើTnT មានលក្ខណៈ ដូចម្ដេច ហើយតើភាគីពាក់ព័ន្ធយល់ឃើញយ៉ាងណាចំពោះឥទ្ធិពលរបស់វា?***

TnT គឺជាប្រព័ន្ធអន្តរាគមន៍ឌីជីថល ដែលក្រសួងអប់រំ យុវជន និងកីឡាបានដាក់ឱ្យប្រើប្រាស់ដើម្បីគ្រប់គ្រងការផ្គត់ផ្គង់សៀវភៅសិក្សាគោលដល់សាលារដ្ឋនៅប្រទេសកម្ពុជា។

**TnTដំណើរការតាមរយៈវេទិកាចំនួនបី៖**

(១) Telegram chatbot ដែលគ្រប់គ្រងមុខងារសំខាន់ៗរបស់ TnT; (២) Form Assemblyដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់ទាំងអស់ផ្លាស់ប្ដូរទិន្នន័យតម្រូវការសៀវភៅសិក្សាបានយ៉ាងឆាប់រហ័សជាមួយគ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ;និង(៣)ផ្ទាំងគ្រប់គ្រងគេហទំព័រដែលអនុញ្ញាត្តឱ្យមន្ត្រីពាក់ព័ន្ធជួយតាមដានតម្រូវការសៀវភៅសិក្សា និងដំណើរការផ្គត់ផ្គង់។

ការស្រាវជ្រាវនេះបានរកឃើញ**ឥទ្ធិពលវិជ្ជមានចំនួន៣ធំៗ**ដែលទទួលបានមកពីការប្រើប្រាស់ TnT។

**១**

**TnT បានសន្សំពេលវេលា ហិរញ្ញវត្ថុ និងធនធានមនុស្ស។** តាមរយៈការផ្លាស់ប្ដូរសំណើ សៀវភៅសិក្សានិងដំណើរការចែកចាយមកតាមអ៊ីនធឺណិត នាយកសាលាលែងចំណាយពេលវេលាច្រើនលើការងាររៀបចំឯកសារទៀតហើយ។ បច្ចុប្បន្ននេះក្រសួងអាចបញ្ចប់ការព្យាករណ៍ និងធ្វើផែនការសៀវភៅសិក្សាគោលក្នុងរយៈពេលពី***២ទៅ៤សប្ដាហ៍តែប៉ុណ្ណោះជៀសជាងប្រើពេល ៣ ទៅ ៤ ខែ***។

**២**

**TnT បានជួយកែលម្អលទ្ធភាពទទួលបានសៀវភៅសិក្សាគោលសម្រាប់សិស្ស។** ប្រមាណជា ៧៥%នៃនាយកសាលាបានរាយការណ៍ថាសិស្សរបស់ពួកគេអាចទទួលបានសៀវភៅសិក្សាគោលគ្រប់មុខវិជ្ជាទាំងអស់ ខណៈពេលដែលមាន ៥៧%នៃនាយកសាលាក៏បានរាយការណ៍ថាឥឡូវនេះពួកគេអាចទទួលបានសៀវភៅសិក្សាគោលដែលបានស្នើសុំក្នុងរយៈពេលតិចជាងបីខែ។

**៣**

**TnT ក៏បានជួយបង្កើនតម្លាភាព និងគណនេយ្យភាពនៅក្នុងប្រព័ន្ធផ្គត់ផ្គង់សៀវភៅសិក្សាគោលផងដែរ។**TnTអនុញ្ញាតឱ្យមានការទំនាក់ទំនងដោយផ្ទាល់រវាងនាយកសាលា និងគ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ ហើយអាចឱ្យភាគីពាក់ព័ន្ធនៅក្នុងសហគមន៍សាលារៀនអាចពិនិត្យមើលចំនួន និងចំណងជើងសៀវភៅសិក្សាដែលបានផ្ដល់ឱ្យ។

## សំណួរស្រាវជ្រាវទី២ ៖

***តើ TnT ត្រូវបានបង្កើតឡើង និងអនុវត្តដោយរបៀបណា និងក្រោមលក្ខខណ្ឌអ្វីខ្លះ?***

**មានកត្តាសំខាន់ៗប្រាំមួយ ដែលរួមចំណែកដល់ការអភិវឌ្ឍ និងការអនុវត្ត TnT ។**

**កត្តាយុទ្ធសាស្ត្រ៖** (១) ចក្ខុវិស័យរយៈពេលវែង; និង (២) ការរៀបចំផែនការយុទ្ធសាស្ត្រច្បាស់លាស់របស់ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា និងការគាំទ្រ និងការប្តេជ្ញាចិត្តរបស់ពួកគេ ដើម្បីជួយដល់នាយកដ្ឋានពាក់ព័ន្ធទូទាំងថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន។

**កត្តាប្រតិបត្តិការ៖** (៣) វត្តមាននៃបច្ចេកវិទ្យាព័ត៌មាន (អ៊ីនធឺណិត និងកម្មវិធីតេឡេក្រាម); (៤) ការបណ្តុះបណ្តាល និងការកសាងសមត្ថភាព; (៥) ការប្តេជ្ញាចិត្តរបស់អ្នកប្រើប្រាស់ TnT ដើម្បីទទួលយក និងរៀនបច្ចេកវិទ្យាថ្មីៗ និង (៦) កិច្ចសហការរវាងភាគីពាក់ព័ន្ធក្នុងខ្សែច្រវ៉ាក់ ផ្គត់ផ្គង់សៀវភៅសិក្សាគោល។

យើងក៏បានរកឃើញថាជំងឺរាតត្បាតCOVID-19ដើរតួជាអ្នកពន្លឿនផងនិងអ្នករារាំងផង ក្នុងការអភិវឌ្ឍ និងការប្រើប្រាស់ TnT ។

## សំណួរស្រាវជ្រាវទី៣ ៖

***តើបញ្ហាប្រឈមអ្វីខ្លះត្រូវបានគេសង្កេតឃើញ និងដោះស្រាយក្នុងអំឡុងពេលដំណើរការនេះ? តើត្រូវការជំនួយបន្ថែមអ្វីខ្លះសម្រាប់ភាពជោគជ័យរបស់ TnT?***

**មានបញ្ហាប្រឈមសំខាន់ៗប្រាំបីក្នុងការអភិវឌ្ឍ និងអនុវត្ត TnT ។**

**នៅក្នុងដំណាក់កាលអភិវឌ្ឍន៍៖** (១) កង្វះអ្នកជំនាញឌីជីថលក្នុងស្រុក (២) ការស្ទាក់ស្ទើរក្នុងការទទួលយកបច្ចេកវិទ្យាថ្មី និង (៣) ការរំខាននៃការរាតត្បាតជំងឺ Covid-19 ។

**នៅក្នុងដំណាក់កាលនៃការអនុវត្ត៖** (៤) គម្លាតឌីជីថលរវាងសាលារៀននៅតាមទីក្រុងនិងជនបទ (៥) ភាពមិនសូវអំណោយផលនៃផ្ទាំងការងាររបស់ប្រព័ន្ធ TnT (៦) ការចំណាយខ្ពស់សម្រាប់ការកែលម្អប្រព័ន្ធ TnT និងធនធានហិរញ្ញវត្ថុនៅមានកម្រិត (៧) ការបណ្តុះបណ្តាលដល់អ្នកប្រើប្រាស់ និងសម្ភារៈណែនាំនៅលើ TnT នៅមិនទាន់គ្រប់គ្រាន់ និង (៨) កង្វះការចូលរួមក្នុងចំណោមនាយកសាលាមួយចំនួន។

**ការគាំទ្រសំខាន់ៗចំនួនបី** ត្រូវបានអនុម័តដើម្បីកាត់បន្ថយបញ្ហាប្រឈមទាំងនេះ៖ (១) ការបង្កើតក្រុមគាំទ្រ និងការសហការជិតស្និទ្ធ នៅថ្នាក់ស្រុក និងសាលារៀន ដើម្បីជួយអ្នកប្រើប្រាស់ TnT ផ្សេងទៀត (២) ការផ្ទេរអតិរេកសៀវភៅសិក្សាទៅសាលារៀនដែលមានការខ្វះខាត និង (៣) ប្រើប្រាស់ធនធានក្នុងស្រុក ដើម្បីដោះស្រាយចន្លោះប្រហោងក្នុងការផ្គត់ផ្គង់សៀវភៅ និងលទ្ធភាពក្នុងការប្រើប្រាស់អ៊ីនធឺណិត។

## អនុសាសន៍

**ដើម្បីអោយប្រតិបត្តិការ TnT កាន់តែប្រសើរឡើងនាពេលអនាគត** ក្រសួងអប់រំ យុវជន និងកីឡា គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធផ្សេងទៀតគួរសហការជាមួយគ្នាដើម្បី៖

១ បន្តចែករំលែកចក្ខុវិស័យរយៈពេលវែងនៃការប្រើប្រាស់ប្រព័ន្ធ TnT ។

២ បង្កើតប្រព័ន្ធត្រួតពិនិត្យ និងធានាឱ្យមានលទ្ធភាពប្រើប្រាស់ស្មើភាពគ្នាចំពោះធនធានឌីជីថល។

៣ ផ្តល់ការបណ្តុះបណ្តាល និងការធ្វើបច្ចុប្បន្នភាពប្រព័ន្ធ TnT ដល់អ្នកប្រើប្រាស់ TnT ទាំងអស់។

៤ ពង្រីកការចូលទៅកាន់ការប្រើផ្ទាំងគ្រប់គ្រងប្រព័ន្ធ TnT ទៅកាន់ស្ថាប័នរដ្ឋាភិបាលផ្សេងទៀតដែលពាក់ព័ន្ធ។

**សម្រាប់សក្តានុពលនៅក្នុងការអនុវត្តប្រព័ន្ធ TnT នៅក្នុងប្រទេសដែលមានចំណូលមធ្យមកម្រិតទាប** វាមានសារៈសំខាន់ណាស់ក្នុងការ៖

១ ការបណ្តុះបណ្តាលអ្នកប្រើប្រាស់៖ ការបណ្តុះបណ្តាលតាមអ៊ិនធឺណេតតាមតម្រូវការជាក់ស្តែងគឺជាវិធីសាស្ត្រដ៏មានប្រសិទ្ធភាពមួយ។

២ ប្រើវេទិកាឌីជីថលដែលពេញនិយមឬមានដាក់អោយប្រើប្រាស់ស្រាប់ដោយរដ្ឋាភិបាលនៅក្នុងប្រទេស។

៣ ព្យាយាមសម្របឬអភិវឌ្ឍន៍ប្រព័ន្ធទៅនឹងបរិបទក្នុងស្រុកហើយទាក់ទាញអ្នកជំនាញ និងភាគីពាក់ព័ន្ធក្នុងស្រុកអោយចូលរួមបន្ថែមទៀត ដើម្បីបង្កើននិរន្តរភាពនៃប្រព័ន្ធ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងទៅកាន់ **share.nd@edu**

Suggested Citation:

Bun, Phoury; Song, Sopheak; Lee, Jeongmin; Bender, Penelope (2023). SHARE LIBROS (Learning to Improve Book Resource Operational Systems) Cambodia, Final Brief. University of Notre Dame. Report. https://doi.org/10.7274/

*The University of Notre Dame's (UND) Pulte Institute for Global Development is implementing the SHARE activity in partnership with local higher education and research institutions. Through SHARE and its partners, UND will advance USAID's Learning Priorities as a global good to improve education and learning outcomes as part of cooperative agreement No. 7200AA20CA00025. The contents of this document are the sole responsibility of the Pulte Institute and do not necessarily reflect the views of USAID or the United States Government.*